- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់ប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៩៩៩

ត្រាស់បង្គាប់

មាត្រា ១ ._ តែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា ដែលមានរាយនាមដូចខាងក្រោមនេះ ៖

១-ឯកឧត្តម សំ គឹមហេង ទទួលបន្ទុក អភិវឌ្ឍន៍ជនបទ និងសង្គមកិច្ចមានឋានៈស្មើ រដ្ឋលេខាធិការ ។

២-ឯកឧត្តម នូ សុទណ្ណារ៉ា ទទួលបន្ទុកនយោបាយ សេដ្ឋកិច្ច មហាផ្ទៃ និងការពារជាតិមានឋានៈស្មើ រដ្ឋលេខាធិការ ។

៣-ឯកឧត្តម សោម ឡាទី ទទួលបន្ទុក នីតិកម្ម និងអប់រំ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ ._ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅសៀមរាប អង្គារថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៥៤ អនក្រ.បក ស្តីពីការបង្កើតគ្រុមប្រឹក្សាកំណែទម្រង់ កងយោធពលខេមរភូមិន្ទ

***

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអង្គភាពសំរាប់សំរបសំរួលបញ្ហាកងទ័ពរំសាយ និងសមាហរណកម្ម ចូលក្នុងសង្គមជាតិ អតីតទាហានខ្មែរក្រហម

**សំរេច**

**មាត្រា ១ .-** បង្កើតក្រុមប្រឹក្សា កំណែទំរង់កងយោធពលខេមរភូមិន្ទ ដែលមានសមាសភាពដូចខាងក្រោម :

១-នាយឧត្តមសេនីយ៍ផ្កាយមាស៤ ទៀ បាញ់ ទេសរដ្ឋមន្ត្រីសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន

២-អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាសហប្រធាន

៣-នាយឧត្តមសេនីយ៍ផ្កាយមាស៤ កែ គឹមយ៉ាន អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ជាអនុប្រធាន

៤-ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអនុប្រធាន

៥-ឧត្តមសេនីយ៍ឯក មាស សុផា អគ្គមេបញ្ជាការរងនិងជាមេបញ្ជាការកងទ័ពជើងគោក ជាសមាជិក

៦-ឧត្តមសេនីយ៍ទោ មល់ រឿម ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាសមាជិក

៧-ឧត្តមសេនីយ៍ត្រី ឡុំ គឹមឡឿន អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ជាសមាជិក

**មាត្រា ២ .-** ក្រុមប្រឹក្សាកែទំរង់កងយោធពលខេមរភូមិន្ទ មានភារកិច្ចដូចខាងក្រោម :

-ទទួលបន្ទុកលើកសំណើជូនឯកឧត្តម សហរដ្ឋមន្ត្រី ស្តីពីការកំណែទំរង់សំខាន់ៗ ដែលទាក់ទងទៅ នឹងកំណែទំរង់កងយោធពលខេមរភូមិន្ទ តាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

-ទទួលបន្ទុកសំរបសំរួលតាមដានជាអចិន្ត្រៃយ៍នូវកម្មវិធីកំណែទំរង់

-ដើម្បីអនុវត្ត បេសកកម្មកែទំរង់ កងយោធពលខេមរភូមិន្ទ ដូចបានចែងក្នុងមាត្រា ១ ក្រុមប្រឹក្សាកំណែទំរង់កងយោធពលខេមរភូមិន្ទ ត្រូវបានជួយជាកំលាំងដោយគណៈកម្មការ អនុគណៈកម្មការរំសាយទ័ព នៃកងយោធពលខេមរភូមិន្ទ គណៈកម្មការ និងអនុគណៈកម្ម ការកំណែទំរង់នៃកងយោធពលខេមរភូមិន្ទ ដែលនឹងត្រូវបានបង្កើតឡើងដោយប្រកាសរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងក្រុមប្រឹក្សាបច្ចេកទេសស្រង់ស្ថិតិ និងធ្វើអត្តសញ្ញាប័ណ្ណ ។

-ក្នុងការបំពេញបេសកកម្មដូចបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាកំណែទំរង់ នៃកងយោធពលខេមរភូមិន្ទមានភារកិច្ចជាក់ស្តែងដូចតទៅ ៖

-លើកសំណើស្តីពីការបង្កើត ឬការផ្លាស់ប្តូរគណៈកម្មការរំសាយទ័ព ។

-តម្រង់ទិសសកម្មភាពទាំងអស់របស់គណៈកម្មការរំសាយទ័ព ។ សំរបសំរួល និងត្រួតពិនិត្យមើលលទ្ធផលទាំងអស់របស់គណៈកម្មការ និងអនុគណៈកម្មការនីមួយៗ ។

-លើកសំណើជូនក្រសួងការពារជាតិ អំពីចំណេងអត្ថបទច្បាប់ និងបទបញ្ញត្តិចាំបាច់សំរាប់ដាក់អោយដំណើរការក្នុងការតុះត្រង់ស្ថិតិ និងធ្វើអត្តសញ្ញាប័ណ្ណ ។

មាត្រា ៣ ._ ត្រូវបង្កើតអគ្គលេខាធិការដ្ឋានទទួលបន្ទុក ការងារអចិន្ត្រៃយ៍ដែលមានសមាសភាពដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ឯក ទួន ស៊ីផាន នាយរងសេនាធិការចំរុះ ជាអគ្គលេខាធិការ

២-ឧត្តមសេនីយ៍ឯក ជាំ ឫទ្ធី នាយកទីចាត់ការការងារបុគ្គលិកអគ្គបញ្ជាការដ្ឋាន ជាអគ្គលេខាធិការរង

៣-ឧត្តមសេនីយ៍ឯក ពុត សំអោត នាយក នាយកដ្ឋានបុគ្គលិកក្រសួងការពារជាតិ ជាអគ្គលេខាធិការរង

៤-ឧត្តមសេនីយ៍ត្រី អ៊ួន លន នាយការិយាល័យទី១ កងទ័ពជើងគោក ជាសមាជិក

៥-វរនាវីទោ អ៊ិន ម៉ុនលី នាយការិយាល័យទី ១ កងទ័ពជើងទឹក ជាសមាជិក

៦-វរសេនីយ៍ទោ ញឹម សុវណ្ណ នាយការិយាល័យទី ១ កងទ័ពជើងអាកាស ជាសមាជិក

៧-វរសេនីយ៍ទោ លី នី នាយការិយាល័យទី ១ កងរាជអាវុធហត្ថ ជាសមាជិក

មាត្រា ៤ ._ អគ្គលេខាធិការដ្ឋាន ទទួលបន្ទុកធ្វើជាសេនាធិការផ្ទាល់ របស់ក្រុមប្រឹក្សាកំណែទំរង់កងយោធពលខេមរភូមិន្ទ ហើយមានភារកិច្ចជាក់ស្តែងដូចតទៅ ៖

- ស្រាវជ្រាវ ពិចារណា និងលើកយោបល់ ស្តីពីការកែទំរង់ ជូនក្រុមប្រឹក្សាកំណែទំរង់ កងយោធពលខេមរភូមិន្ទ ។
- ត្រួតពិនិត្យផែនការ និងជំរុញការងារស្រង់ស្ថិតិ និងធ្វើអត្តសញ្ញាណប័ណ្ណ ដើម្បីបំរើការងាររំសាយទ័ព ។
- ណែនាំដំណើរការកម្មវិធីរំសាយទ័ព និងជំរុញគណៈកម្មការ អនុគណៈកម្មការរំសាយទ័ពអោយដំណើរការតាមផែនការកំណត់ ដោះស្រាយរាល់សំណើរបស់គណៈកម្មការ ដែលជួបការលំបាក ។
- តាមដានវាយតំលៃការងារអនុវត្ត ផែនការរបស់អនុគណៈកម្មការ ធ្វើអោយមានប្រសិទ្ធភាពល្អប្រសើរក្នុងការដំណើរការរំសាយទ័ព ។

មាត្រា ៥ ._ ក្រុមប្រឹក្សាកំណែទំរង់ កងយោធពលខេមរភូមិន្ទ កំណត់របៀបវារៈនៃការប្រជុំនានា ដឹកនាំពិភាក្សា និង កំណត់រាល់វិធានការ និងសេចក្តីសំរេចទាំងអស់ ដែលពាក់ព័ន្ធ ។

-សមាជិកទាំងអស់ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ សហប្រធាន ក្រុមប្រឹក្សាភិបាលអភិវឌ្ឍន៍កងរាជអាវុធហត្ថខេមរភូមិន្ទ ។

ការរៀបចំការប្រជុំទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអភិវឌ្ឍន៍កងរាជអាវុធហត្ថខេមរភូមិន្ទ និងការតាមដានការអនុវត្តន៍ផែនការគោលការណ៍ណែនាំទាំងអស់របស់ខ្លួន ត្រូវបានកំណត់ដោយអគ្គលេខាធិការដ្ឋានទទួលបន្ទុកការងារអធិរដ្ឋ ។

មាត្រា ៦ ._ រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងរាជអាវុធហត្ថខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៤៥ អនក្រ.បក
## ស្តីពីការបង្កើតគណៈកម្មការរៀបចំទិវា
## មហោស្រពអង្គរ ឆ្នាំ១៩៩៩-២០០០

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- យោងតាមការចាំបាច់នៃការបោះនុវត្តភាពបើកឆ្នាំសន្តិភាព ទេសចរណ៍ ឆ្លងដំណាច់សតវត្សទី ២០

### សំរេច

មាត្រា ១ ._ បង្កើតគណៈកម្មការរៀបចំទិវាមហោស្រពអង្គរឆ្នាំ ១៩៩៩-២០០០ មួយដែលមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ស៊ុំ ម៉ានិត រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន